ការរៀបចំឲ្យមានការបង្រៀនភាសាខ្មែរ ពិតជាមានអត្ថប្រយោជន៍ណាស់សម្រាប់វិទ្យាស្ថាន និងអ្នកហាត់ការបរទេស។ វិធីនេះ អាចជួយបង្កើនប្រសិទ្ធភាពការចូលរួមក្នុងសង្គម និងការរៀនសូត្ររបស់អ្នកហាត់ការ ក៏ដូចជាការចូលរួមចំណែករបស់ពួកគេក្នុងការងារស្រាវជ្រាវរបស់វិទ្យាស្ថាន។ សរុបមកការចុះកម្មសិក្សា មិនមែនគ្រាន់តែជាការបញ្ជូននិស្សិតទៅបរទេសដោយពុំមានការយល់ដឹងអំពីវប្បធម៌ និងសាវតាររបស់ប្រទេស ឬស្ថាប័ននោះទេ។ ទំនាក់ទំនងរវាងមនុស្ស និងទំនុកចិត្តរឹងមាំ ជាកត្តាដ៏សំខាន់ក្នុងការបង្កើត និងទ្រទ្រង់កម្មវិធីចុះកម្មសិក្សាអន្តរជាតិដូចក្នុងករណីអ្នកហាត់ការកូរ៉េខាងត្បូង នៅវិទ្យាស្ថាន CDRI ជាដើម។

ករណីសិក្សានេះ បានផ្ដោតទៅលើអ្នកហាត់ការកូរ៉េខាងត្បូង នៅវិទ្យាស្ថាន CDRI ត្រឹមតែ ៦នាក់ ប៉ុណ្ណោះ។ ដូច្នេះហើយ វាពិតជាពិបាកក្នុងការយកលទ្ធផល ដែលរកឃើញទៅធ្វើសេចក្ដីសន្និដ្ឋានទូទៅ សម្រាប់អ្នកហាត់ការបរទេសផ្សេងទៀតនៅវិទ្យាស្ថាន CDRI ឬសម្រាប់ចលិតភាពរបស់អ្នកហាត់ការអន្តរជាតិទាំងមូលណាស់។ ម្យ៉ាងទៀត ដោយសារអ្នកនិពន្ធពីររូបជាអ្នកស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI លទ្ធផលស្រាវជ្រាវគួរត្រូវបានប្រើប្រាស់ដោយប្រុងប្រយ័ត្ន។ ចំណុចខ្វះចន្លោះមួយទៀតនៃការស្រាវជ្រាវនេះ គឺ សម្ភាសន៍ត្រូវបានធ្វើឡើងជាពីរដំណាក់កាលក្នុងរយៈពេលខុសគ្នា។ ការសិក្សានាពេលអនាគតគួរពិចារណាពីចំណុចទាំងនេះ និងប្រើវិធីសាស្ត្រប្រៀបធៀបមួយតាមរយៈការស្រាវជ្រាវពីបទពិសោធន៍ របស់អ្នកហាត់ការអន្តរជាតិមកពីប្រទេសផ្សេងៗទៀត។

លើសពីនេះទៀត CDRI ជាករណីពិសេសមួយ ព្រោះវិទ្យាស្ថាននេះ ត្រូវបានបង្កើតឡើងជាផ្លូវការនៅឆ្នាំ២០០០ ដោយអនុក្រឹត្យលេខ៩៤ ក្នុងលក្ខណៈជាវិទ្យាស្ថានស្រាវជ្រាវផ្នែកគោលនយោបាយ ឯករាជ្យ មិនស្វែងរកប្រាក់ចំណេញ ដែលរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ផ្ដល់សេវាកម្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រទេស និងធ្វើការស្រាវជ្រាវ និងវិភាគដើម្បីផ្ដល់ព័ត៌មានដល់ការកសាងគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ដោយមូលហេតុនេះ វិទ្យាស្ថាន CDRI មានបទពិសោធន៍ជាយូរឆ្នាំមកហើយក្នុងការទទួលអ្នកស្រាវជ្រាវ និងអ្នកហាត់ការបរទេស និងមានឈ្មោះល្បីល្បាញក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិលើការស្រាវជ្រាវមានគុណភាពខ្ពស់។ ដូច្នេះការសិក្សានាពេលអនាគត គួរពិនិត្យមើលពីកម្មវិធីចុះកម្មសិក្សាអន្តរជាតិ នៅតាមស្ថាប័នស្រាវជ្រាវ និងមិនមែនស្រាវជ្រាវដទៃទៀតនៅកម្ពុជា។

### ឯកសារយោង

Creswell, John W. 2007. Qualitative Inquiry and Research Design: Choosing among Five Approaches. 3rd edition. Thousand Oaks, CA: Sage.

D'Abate, Caroline P., Mark A. Youndt and Kathryn E. Wenzel. 2009. "Making the Most of an Internship: An Empirical Study of Internship Satisfaction." *Academy of Management Learning & Education* 8 (4): 527–539.

Fagan, Thomas K., and Paula Sachs Wise. 2007. *School Psychology: Past, Present, and Future.* 3rd edition. Bethesda, MA: National Association of School Psychologists.

Feldman, Daniel C., William R. Folks and William H. Turnley. 1999. "Mentor-Protege Diversity and Its Impact on International Internship Experiences." *Journal of Organizational Behavior* 20 (5): 597–611.

*តទៅទំព័រ ១៧*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសូចនាករសេដ្ឋកិច្ចនៃប្រទេសធំៗមួយចំនួន និងបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍។ ជារួមនៅត្រីមាសទី១ ឆ្នាំ២០២០ កំណើន ផសស ក្នុងប្រទេសជ្រើសរើសទាំងអស់បានធ្លាក់ចុះខ្លាំងរហូតដល់កម្រិតទាបបំផុត។

ក្នុងចំណោមប្រទេសអាស៊ានជ្រើសរើស សិង្ហបុរីមានអត្រាកំណើនទាបបំផុតរហូតដល់ ដក ២,២% បន្ទាប់មកគឺ ថៃ (ដក ១,៨%) ម៉ាឡេស៊ី (០,៧%) ឥណ្ឌូនេស៊ី (២,០%)។ ទិន្នន័យថ្មីបំផុតលើកំណើន ផសស នៅ កម្ពុជា និង វៀតណាម មិនទាន់មាននៅឡើយទេ នៅពេលចងក្រងអត្ថបទនេះ។ បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ផសស សិង្ហបុរីធ្លាក់ចុះអស់ ៣,៥ឯកតាភាគរយ ផសស ថៃធ្លាក់ចុះ ៤,៦ឯកតាភាគរយ ម៉ាឡេស៊ីធ្លាក់ចុះ ៣,៨ឯកតាភាគរយ ឥណ្ឌូនេស៊ីធ្លាក់ចុះ ២,១ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន ផសស សិង្ហបុរីធ្លាក់ចុះ ៣,០ឯកតាភាគរយ ថៃធ្លាក់ចុះ ៣,៤ឯកតាភាគរយ ម៉ាឡេស៊ីធ្លាក់ចុះ ២,៩ឯកតាភាគរយ ឥណ្ឌូនេស៊ីធ្លាក់ចុះ ២,០ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស ហុងកុងមានអត្រាកំណើន ផសស ទាបជាងគេ (ដក ៨,៩%) បន្ទាប់មកគឺ ចិន (ដក ៦,៨%) កូរ៉េខាងត្បូង (១,៣%) តៃវ៉ាន់ (១,៥%)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាកំណើន ផសស នៅហុងកុងធ្លាក់ចុះ ៩,៥ឯកតាភាគរយ ចិនធ្លាក់ចុះ ១៣,២ឯកតាភាគរយ កូរ៉េខាងត្បូងធ្លាក់ចុះ ០,៥ឯកតាភាគរយ តៃវ៉ាន់ ធ្លាក់ចុះ ០,២ ឯកតាភាគរយ។ ធៀបនឹងត្រីមាសមុន អត្រាកំណើន ផសស នៅហុងកុងធ្លាក់ចុះ ៦,០ឯកតាភាគរយ ចិនធ្លាក់ចុះ ១២,៨ឯកតាភាគរយ កូរ៉េខាងត្បូងធ្លាក់ចុះ ២,១ឯកតាភាគរយ តៃវ៉ាន់ធ្លាក់ចុះ ១,៨ឯកតាភាគរយ។

សម្រាប់ប្រទេសឧស្សាហកម្មជ្រើសរើស តំបន់អឺរ៉ូ១២ មានអត្រាកំណើន ផសស ទាបជាងគេ (ដក ៣,៣%) បន្ទាប់មកគឺ ជប៉ុន (ដក ២,០%) សហរដ្ឋអាមេរិក (០,៣)។ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ អត្រាកំណើន ផសស នៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ៤,៥ឯកតាភាគរយ ជប៉ុនធ្លាក់ចុះ ២,៩ឯកតាភាគរយ សហរដ្ឋអាមេរិកធ្លាក់ចុះ ២,៩ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន អត្រាកំណើន ផសស នៅតំបន់អឺរ៉ូ១២ ធ្លាក់ចុះអស់ ៤,៣ឯកតាភាគរយ ជប៉ុនធ្លាក់ចុះ ១,៣ឯកតាភាគរយ សហរដ្ឋអាមេរិកធ្លាក់ចុះ ២,០ឯកតាភាគរយ។

អត្ថបទនេះ រៀបរៀងដោយ រឿន ណារិទ្ធ ជាអ្នកស្រាវជ្រាវ និង ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្មដើម្បីអភិវឌ្ឍន៍ នៅវិទ្យាស្ថាន CDRI។

## អតិផរណាក្នុងពិភពលោក

សម្រាប់ប្រទេសអាស៊ានជ្រើសរើស បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ ថៃ និង សិង្ហបុរី មានអត្រាអតិផរណាធ្លាក់ចុះ រីឯ កម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង វៀតណាម មានអតិផរណាកើនឡើង។ វៀតណាមមានអត្រាអតិផរណាខ្ពស់ជាងគេ (៥,៦%) បន្ទាប់មកគឺ កម្ពុជា (៣,០%) ឥណ្ឌូនេស៊ី (២,៩%) ម៉ាឡេស៊ី (០,៩%) សិង្ហបុរី (០,៤%) ថៃ (០,៤)។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អត្រាអតិផរណានៅវៀតណាមកើនឡើង ៣,០ឯកតាភាគរយ កម្ពុជាកើន ១,១ឯកតាភាគរយ ម៉ាឡេស៊ីកើន ១,២ឯកតាភាគរយ ឥណ្ឌូនេស៊ីកើន ០,៣ឯកតាភាគរយ ប៉ុន្តែអត្រាអតិផរណានៅសិង្ហបុរី ធ្លាក់ចុះ ០,១ឯកតាភាគរយ ថៃធ្លាក់ចុះ ០,៣ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន វៀតណាមមានអត្រាអតិផរណាកើនឡើង ១,៩ឯកតាភាគរយ កម្ពុជាមានអត្រាអតិផរណាកើន ០,៩ឯកតាភាគរយ រីឯ ឥណ្ឌូនេស៊ី និង ថៃ មានអត្រាអតិផរណានៅថេរ ហើយ ម៉ាឡេស៊ីមានអត្រាអតិផរណាធ្លាក់ចុះ ០,១ឯកតាភាគរយ សិង្ហបុរីធ្លាក់ចុះ ០,២ឯកតាភាគរយ។

ក្នុងចំណោមប្រទេសអាស៊ីជ្រើសរើស ចិនមានអត្រាអតិផរណាខ្ពស់ជាងគេ (៤,៤%) បន្ទាប់មកគឺ ហុងកុង (២,០%) កូរ៉េខាងត្បូង (១,២%) តៃវ៉ាន់(០,៦)។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅចិនកើន ២,៦ឯកតាភាគរយ កូរ៉េខាងត្បូងកើន ០,៦ឯកតាភាគរយ តៃវ៉ាន់កើន ០,៣ឯកតាភាគរយ រីឯអត្រាអតិផរណានៅហុងកុងធ្លាក់ចុះ ០,២ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុនអត្រាអតិផរណានៅចិនកើនឡើង ០,១ឯកតាភាគរយ កូរ៉េខាងត្បូង កើន ០,៩ឯកតាភាគរយ រីឯអត្រាអតិផរណានៅហុងកុងធ្លាក់ចុះ ១,០ឯកតាភាគរយ តៃវ៉ាន់ធ្លាក់ចុះ ០,១ឯកតាភាគរយ។

ក្នុងចំណោមប្រទេសឧស្សាហកម្មជ្រើសរើស សហរដ្ឋអាមេរិកមានអត្រាអតិផរណាខ្ពស់ជាងគេ (២,១%) បន្ទាប់មកគឺ តំបន់អឺរ៉ូ១២ (១,១%) ជប៉ុន (០,៥%)។ ធៀបនឹងកាលពីមួយឆ្នាំមុន អត្រាអតិផរណានៅសហរដ្ឋអាមេរិកកើនឡើង ០,៤ឯកតាភាគរយ ហើយ ជប៉ុនកើន ០,២ឯកតាភាគរយ ប៉ុន្តែនៅតំបន់អឺរ៉ូ១២ អត្រាអតិផរណាបានធ្លាក់ចុះ ០,៣ឯកតាភាគរយ។ បើធៀបនឹងត្រីមាសមុន អត្រាអតិផរណានៅសហរដ្ឋអាមេរិក និងជប៉ុននៅថេរ ប៉ុន្តែនៅតំបន់អឺរ៉ូ១២ វាកើនឡើង។

## អត្រាប្តូរប្រាក់

ធៀបនឹងកាលពីមួយឆ្នាំមុន ប្រាក់បាតថៃ ដុល្លារតៃវ៉ាន់ និងប្រាក់យ៉េនជប៉ុន បានឡើងថ្លៃទល់នឹងដុល្លារអាមេរិក រីឯប្រាក់រៀលកម្ពុជា ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ប្រាក់រីងហ្គិតម៉ាឡេស៊ី ប្រាក់ដុងវៀតណាម ប្រាក់យ័នចិន ដុល្លារហុងកុង ប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់អឺរ៉ូ បានចុះថ្លៃ។ ប្រាក់រៀលកម្ពុជាបានចុះថ្លៃ ១,៤% ដល់ ៤.០៦៤,១រៀល/ដុល្លារ ហើយប្រាក់ដុងវៀតណាមចុះថ្លៃ ២,០% ដល់ ២៣.៣៥១,០ដុង/ដុល្លារ ប៉ុន្តែប្រាក់បាតថៃឡើងថ្លៃ ១,៣% ដល់ ៣១,២បាត/ដុល្លារ។ បើធៀបនឹងត្រីមាសមុន ប្រាក់រៀលកម្ពុជាចុះថ្លៃ ០,០១% ទល់នឹងដុល្លារអាមេរិក ប្រាក់បាតថៃចុះថ្លៃ ៣,០% ហើយប្រាក់ដុងវៀតណាមចុះថ្លៃ ០,៦%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ កៅស៊ូ ប្រេងឆៅ សាំង និង ម៉ាស៊ូត បានចុះថ្លៃ រីឯ ពោត ប្រេងដូងប្រេង អង្ករ និងសណ្តែកសៀង បានឡើងថ្លៃ។ កៅស៊ូបានចុះថ្លៃ ៤,៣% ប្រេងឆៅចុះថ្លៃ ១៨,៨% សាំងចុះថ្លៃ ១៦,៤% ម៉ាស៊ូតចុះថ្លៃ ២០,៨% ប៉ុន្តែពោតឡើងថ្លៃ ០,១% ប្រេងដូងប្រេងឡើងថ្លៃ ២៣,៥% អង្ករឡើងថ្លៃ ១២,៨% សណ្តែកសៀងឡើងថ្លៃ ២,១%។ បើធៀបនឹងត្រីមាសមុន កៅស៊ូចុះថ្លៃ ២,៥% ប្រេងឆៅចុះថ្លៃ ១៨,៦% សាំងចុះថ្លៃ ២១,០% ម៉ាស៊ូតចុះថ្លៃ ២០,៦% ប៉ុន្តែពោតឡើងថ្លៃ ០,៥% ប្រេងដូងប្រេងឡើងថ្លៃ ៦,៥% អង្ករឡើងថ្លៃ ៨,៧% ហើយសណ្តែកសៀងឡើងថ្លៃ ៣,៩%។

តារាង១៖ កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.3 | 7.4 | 7.1 | 7.0 | 7.0 | 7.0 | 7.5 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.3 | 5.8 | 5.2 | 4.8 | 5.0 | 5.1 | 5.2 | 5.1 | 5.0 | 5.0 | 5.0 | 3.0 |
| ម៉ាឡេស៊ី | 5.4 | 4.6 | 6.0 | 4.9 | 4.3 | 5.9 | 4.8 | 4.5 | 4.9 | 4.4 | 3.6 | 0.7 |
| សិង្ហបុរី | 1.3 | 3.8 | 3.0 | 2.0 | 2.0 | 3.8 | 3.2 | 1.3 | 0.1 | 0.5 | 0.8 | -2.2 |
| ថៃ | 6.8 | 2.8 | 1.6 | 2.8 | 3.2 | 3.8 | 4.1 | 2.8 | 2.3 | 2.4 | 1.6 | -1.8 |
| វៀតណាម | 5.2 | 5.4 | 5.9 | 6.6 | 6.1 | 6.6 | 7.2 | 6.8 | 6.7 | 7.3 | 7.0 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 7.8 | 7.7 | 7.3 | 7.0 | 6.7 | 6.9 | 6.6 | 6.4 | 6.2 | 6.0 | 6.0 | -6.8 |
| ហុងកុង | 2.9 | 3.0 | 2.3 | 2.3 | 1.7 | 2.8 | 3.1 | 0.6 | 0.5 | 2.9 | -2.9 | -8.9 |
| កូរ៉េខាងត្បូង | 2.1 | 2.8 | 3.4 | 2.6 | 2.6 | 3.0 | 3.0 | 1.8 | 2.1 | 2.0 | 3.4 | 1.3 |
| តៃវ៉ាន់ | 1.2 | 2.2 | 3.5 | 0.6 | 1.2 | 2.8 | 2.6 | 1.7 | 2.4 | 3.0 | 3.3 | 1.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | -0.5 | 0.1 | 0.7 | 1.3 | 1.6 | 2.3 | 1.9 | 1.2 | 1.1 | 1.2 | 1.0 | -3.3 |
| ជប៉ុន | 1.7 | 1.7 | 0.6 | 0.3 | 0.9 | 1.8 | 0.6 | 0.9 | 1.2 | 1.7 | -0.7 | -2.0 |
| សហរដ្ឋអាមេរិក | 2.1 | 1.8 | 2.4 | 2.3 | 1.6 | 2.3 | 3.0 | 3.2 | 2.3 | 2.1 | 2.3 | 0.3 |

Sources: International Monetary Fund; *Economist*; countries' statistics offices

តារាង២៖ អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 3.0 | 3.0 | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 1.8 | 2.0 | 2.1 | 3.0 |
| ឥណ្ឌូនេស៊ី | 4.3 | 7.0 | 6.4 | 6.4 | 3.5 | 3.8 | 3.2 | 2.6 | 3.1 | 3.4 | 2.9 | 2.9 |
| ម៉ាឡេស៊ី | 1.7 | 2.1 | 3.2 | 2.1 | 2.1 | 3.9 | 1.0 | -0.3 | 0.6 | 1.3 | 1.0 | 0.9 |
| សិង្ហបុរី | 4.6 | 2.3 | 1.0 | -0.5 | -0.8 | 0.6 | 0.4 | 0.5 | 0.8 | 0.5 | 0.6 | 0.4 |
| ថៃ | 3.0 | 2.2 | 1.9 | -0.9 | 0.2 | 0.7 | 1.1 | 0.7 | 1.1 | 0.6 | 0.4 | 0.4 |
| វៀតណាម | 9.3 | 6.6 | 4.8 | 0.6 | 2.7 | 3.4 | 3.6 | 2.6 | 2.7 | 2.2 | 3.7 | 5.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 2.7 | 2.6 | 2.0 | 1.4 | 2.0 | 1.6 | 2.1 | 1.8 | 2.6 | 2.9 | 4.3 | 4.4 |
| ហុងកុង | 4.1 | 4.0 | 4.4 | 3.1 | 2.5 | 1.7 | 2.4 | 2.2 | 2.7 | 3.4 | 3.0 | 2.0 |
| កូរ៉េខាងត្បូង | 2.1 | 1.1 | 1.3 | 0.7 | 0.8 | 2.0 | 1.4 | 0.6 | 0.7 | 0.1 | 0.3 | 1.2 |
| តៃវ៉ាន់ | 1.9 | 0.8 | 1.5 | 0.6 | 1.4 | 0.6 | 1.4 | 0.3 | 0.8 | 0.4 | 0.7 | 0.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.5 | 1.4 | 0.4 | 0.0 | 0.3 | 1.5 | 1.8 | 1.4 | 1.4 | 1.0 | 1.0 | 1.1 |
| ជប៉ុន | 0.0 | 0.4 | 2.8 | 0.9 | -0.1 | 0.6 | 1.0 | 0.3 | 0.7 | 0.3 | 0.5 | 0.5 |
| សហរដ្ឋអាមេរិក | 2.1 | 1.5 | 1.6 | 0.0 | 1.2 | 2.1 | 2.5 | 1.7 | 1.8 | 1.7 | 2.1 | 2.1 |

Sources: International Monetary Fund; *Economist*; National Institute of Statistics

តារាង៣៖ អត្រាប្ដូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១២-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4037.8 | 4027.2 | 4037.6 | 4060.4 | 4053.6 | 4047.0 | 4045.0 | 4006.6 | 4052.1 | 4086.8 | 4063.7 | 4064.1 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9363.0 | 10419.2 | 11,850.2 | 13394.8 | 13338.3 | 13379.8 | 14227.6 | 14127.8 | 14246.8 | 14117.6 | 14060.5 | 14220.3 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.1 | 3.1 | 3.3 | 3.9 | 4.1 | 4.3 | 4.0 | 4.1 | 4.1 | 4.2 | 4.2 | 4.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.2 | 1.3 | 1.3 | 1.4 | 1.4 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 31.1 | 30.7 | 32.5 | 34.2 | 35.3 | 33.9 | 32.3 | 31.6 | 31.6 | 30.7 | 30.3 | 31.2 |
| វៀតណាម (ដុង) | 20856.9 | 20990.3 | 21,138.2 | 21917.7 | 22507.5 | 22645.9 | 22663.3 | 22902.9 | 23255.5 | 23258.3 | 23217.3 | 23351.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន) | 6.3 | 6.1 | 6.2 | 6.3 | 6.6 | 6.8 | 6.6 | 6.7 | 6.8 | 7.0 | 7.0 | 7.0 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1126.6 | 1095.0 | 1053.6 | 1131.9 | 1161.0 | 1130.5 | 1099.9 | 1125.0 | 1165.4 | 1193.4 | 1174.7 | 1191.5 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់) | 29.6 | 29.7 | 30.3 | 31.8 | 32.3 | 30.4 | 30.1 | 30.8 | 31.1 | 31.2 | 30.5 | 30.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 79.8 | 97.6 | 105.9 | 121.0 | 108.8 | 112.1 | 110.4 | 110.1 | 109.9 | 107.3 | 108.7 | 109.0 |

Sources: International Monetary Fund; *Economist*; National Bank of Cambodia

តារាង៤៖ ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១២-២០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | | | | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No.2) - USA (ដុល្លារ/តោន) | 298.4 | 259.4 | 192.9 | 169.8 | 159.2 | 154.5 | 164.4 | 167.5 | 175.9 | 170.1 | 166.8 | 167.6 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (ដុល្លារ/តោន) | 999.3 | 856.9 | 821.4 | 622.7 | 643.6 | 714.7 | 638.7 | 586.9 | 568.1 | 570.1 | 680.2 | 724.7 |
| កៅស៊ូ SMR 5 (ដុល្លារ/តោន) | 3200.7 | 2575.3 | 1755.6 | 1392.7 | 1416.1 | 1688.3 | 1401.4 | 1436.6 | 1549.5 | 1389.7 | 1410.1 | 1374.4 |
| អង្ករ (Thai 100% B) - បាងកក (ដុល្លារ/តោន) | 594.8 | 533.8 | 434.9 | 395.5 | 406.7 | 452.3 | 444.2 | 426.7 | 430.0 | 439.7 | 442.7 | 481.3 |
| សណ្ដែកសៀង (US No.1) - USA (ដុល្លារ/តោន) | 591.4 | 538.4 | 491.8 | 390.4 | 405.7 | 400.6 | 405.4 | 353.3 | 347.8 | 339.7 | 347.3 | 360.7 |
| ប្រេងឆៅ - OPEC spot (ដុល្លារ/ធុង) | 109.5 | 105.9 | 96.2 | 49.6 | 40.7 | 52.6 | 69.5 | 60.5 | 65.1 | 59.7 | 60.3 | 49.1 |
| សាំង - US Gulf Coast (សេនដុល្លារ/លីត្រ) | 74.6 | 71.2 | 65.6 | 41.0 | 35.2 | 42.4 | 49.6 | 40.9 | 49.4 | 46.0 | 43.3 | 34.2 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេនដុល្លារ/លីត្រ) | 80.7 | 78.4 | 71.5 | 41.7 | 34.8 | 42.9 | 53.8 | 49.5 | 51.1 | 48.9 | 49.4 | 39.2 |

Sources: Food and Agriculture Organisation; US Energy Information Administration